# ចាំយាមដោយនូវគ្រប់ទាំងសេចក្តីខ្ជាប់ខ្ជួន

(អេភេសូ 6:18)

*អែលឌើរ ដេវីឌ អេ បែតណា*

*នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

ថ្មីៗនេះ ពេលខ្ញុំកំពុងតែបើកឡាន មានគ្រាប់ភ្លៀងធ្លាក់ចុះមក ដោយសារតែព្យុះភ្លៀងបាចសាច នៅលើកញ្ចក់ឡាន។ នៅខាងផ្លូវ មានសញ្ញាអេឡិចត្រូនិចមួយ ដាក់បង្ហាញការព្រមានភ្លាមថា៖ «មានផ្លុក ទឹកនៅខាងមុខ»។ នៅលើផ្លូវដែលខ្ញុំកំពុងបើកបរនោះ មានសភាពដូចជាមានសុវត្ថិភាព។ ប៉ុន្តែព័ត៌មានដ៏ សំខាន់នេះ អាចជួយខ្ញុំឱ្យរៀបចំខ្លួន សម្រាប់គ្រោះថ្នាក់ដោយចៃដន្យមួយ ដែលខ្ញុំមិនបានរំពឹងទុក ហើយ មើលមិនឃើញ។ នៅពេលខ្ញុំបន្តបើកបរឆ្ពោះទៅកាន់គោលដៅរបស់ខ្ញុំ ខ្ញុំបានបើកយឺតៗ ហើយរកមើល ផ្លាកសញ្ញាគ្រោះថ្នាក់ផ្សេងទៀត ដោយយកចិត្តទុកដាក់។

សញ្ញាព្រមានពីដំបូង គឺជាភស្តុតាងនៅក្នុងទិដ្ឋភាពជាច្រើននៃជីវិតរស់នៅរបស់យើង។ ឧទាហរណ៍ ការគ្រុនក្តៅ អាចជារោគសញ្ញាដំបូងនៃការឈឺ ឬជម្ងឺ។ សញ្ញាចង្អុលបង្ហាញអំពីទីផ្សារពលកម្ម និងខាង ហិរញ្ញវត្ថុផ្សេងៗ ត្រូវបានប្រើប្រាស់ ដើម្បីព្យាករអំពីទំនោររបស់សេដ្ឋកិច្ចក្នុងតំបន់ និងសេដ្ឋកិច្ចជាតិនា ពេលអនាគត។ ហើយអាស្រ័យទៅលើតំបន់ នៃពិភពលោកដែលយើងរស់នៅ នោះយើងអាចទទួលបាន នូវការព្រមានអំពី ការបាក់ធ្លាក់ផ្ទាំងទឹកកក ខ្យល់ព្យុះ រលកស៊ូណាមិ ភ្នំភ្លើង ឬព្យុះទឹកកក។

យើងត្រូវបានប្រទានពរផងដែរ ជាមួយនឹងការព្រមានជាមុនខាងវិញ្ញាណ ដែលជាប្រភពមួយនៃការការពារ និងការដឹកនាំនៅក្នុងជីវិតរបស់យើង។ ចូរនឹកចាំអំពីរបៀប ដែលណូអេ ត្រូវបានព្រះមានបន្ទូលប្រាប់ជា មុន អំពីអ្វីៗដែលមើលមិនឃើញនៅឡើយ ហើយគាត់បាន «ធ្វើទូកមួយយ៉ាងធំ សម្រាប់នឹងជួយសង្គ្រោះ ដល់ពួកគ្រួសាររបស់លោក» (ហេព្រើរ 11:7)។

លីហៃ ត្រូវបានព្រមានឱ្យចាកចេញពីយេរូសាឡិម ហើយនាំគ្រួសាររបស់លោកទៅក្នុងទីរហោស្ថាន ដោយ សារតែប្រជាជនដែលលោកបានប្រកាសប្រាប់អំពីការប្រែចិត្ត ចង់រកសម្លាប់លោក (សូមមើលនីហ្វៃទី 1 2:1--2)។

ព្រះអង្គសង្គ្រោះផ្ទាល់ ត្រូវបានរួចជីវិត តាមរយៈការព្រមានរបស់ទេវតា។ «នោះទេវតានៃព្រះអម្ចាស់ក៏ លេចមក ពន្យល់សប្តិប្រាប់យ៉ូសែបថា ចូរក្រោកឡើងនាំបុត្រតូច និងមាតាទ្រង់ រត់ទៅឯស្រុកអេស៊ីព្ទទៅ ឱ្យនៅស្រុកនោះទាល់តែយើងប្រាប់ ត្បិតហេរ៉ូឌ នឹងរកសម្លាប់បុត្រតូច» (ម៉ាថាយ 2:13)។

ចូរពិចារណាអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់ នៅក្នុងវិវរណៈ ដែលបានស្គាល់ថាជា ពាក្យសំដីនៃប្រាជ្ញាវាង

ថែថា៖ «ពីព្រោះតែអំពើអាក្រក់ទាំងឡាយ និងផែនការទាំងឡាយ ដែលមាន ហើយនឹងមាននៅក្នុងដួងចិត្តមនុស្ស ដែលរួមគំនិតប្រព្រឹត្តអំពើទុច្ចរិត នៅថ្ងៃចុងក្រោយបង្អស់ ទើបយើងបានព្រមានដល់អ្នក ហើយហាមអ្នកទុកជាមុន ដោយប្រទានដល់អ្នក នូវពាក្យសំដីនៃប្រាជ្ញាវាងវៃ តាមរយៈវិវរណៈ» (គ. និង ស. 89:4)។

ការព្រមានខាងវិញ្ញាណ គួរតែដឹកនាំទៅរកការចាំមើលដោយប្រុងប្រយ័ត្នថែមទៀត។ អ្នក និងខ្ញុំ រស់នៅក្នុង «ថ្ងៃនៃការព្រមាន» (គ. និង ស. 63:58)។ ហើយដោយសារតែយើងធ្លាប់បាន ហើយនឹងត្រូវបានព្រមាន នោះយើងត្រូវតែ «ចាំយាមដោយនូវគ្រប់ទាំងសេចក្ដីខ្ជាប់ខ្ជួន» (អេភេសូ 6:18) ដូចជាសាវកប៉ុលបានព្រមាន។

ខ្ញុំអធិស្ឋានសុំការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលខ្ញុំពិពណ៌នាអំពីប្រព័ន្ធនៃការព្រមានជាមុនខាងវិញ្ញាណ ដែលអាចជួយដល់ឪពុកម្ដាយ នៅក្នុងស៊ីយ៉ូន ដើម្បីចាំយាម និងបានយល់អំពីកូនចៅរបស់ពួកគេ។ ប្រព័ន្ធនៃការព្រមានជាមុននេះ អនុវត្តចំពោះកូនៗគ្រប់វ័យ ហើយមាននូវកត្តាមូលដ្ឋានចំនួនបីគឺ៖ (1) ការអាន និងការនិយាយអំពីព្រះគម្ពីរមរមនជាមួយនឹងកូនចៅរបស់អ្នក (2)ការថ្លែងទីបន្ទាល់អំពីសេចក្ដីពិតនៃដំណឹងល្អ ចេញពីក្នុងចិត្តដោយឯកឯង ជាមួយនឹងកូនចៅរបស់អ្នក (3)ការអញ្ជើញកូនចៅ ដែលជាអ្នករៀនដំណឹងល្អ ឱ្យធ្វើសកម្មភាព មិនមែនឱ្យទទួលសកម្មភាពទេ។ ឪពុកម្ដាយដែលធ្វើនូវរឿងទាំងនេះដោយស្មោះត្រង់នឹងត្រូវបានប្រទានពរឱ្យស្គាល់សញ្ញាដំបូងនៃការរីកចំរើនខាងវិញ្ញាណ ឬឧបសគ្គទាំងឡាយជាមួយនឹងកូនចៅរបស់ពួកគេ ហើយរៀបចំខ្លួនកាន់តែល្អ ដើម្បីទទួលការបំផុសគំនិត ក្នុងការពង្រឹង និងជួយដល់កូនចៅទាំងឡាយនោះ។

កត្តា #1៖ ការអាន និងការនិយាយអំពីព្រះគម្ពីរមរមន

ព្រះគម្ពីរមរមន មាននូវភាពពេញលេញនៃដំណឹងល្អរបស់ព្រះអង្គសង្គ្រោះ ហើយគឺជាព្រះគម្ពីរតែមួយគត់ ដែលព្រះអម្ចាស់ផ្ទាល់ បានធ្វើទីបន្ទាល់ថាជាការពិត (សូមមើល គ. និង ស. 17:6)។ ជាការពិតណាស់ ព្រះគម្ពីរមរមន គឺជា មូលដ្ឋាននៃសាសនារបស់យើង។

អំណាចនៃការបញ្ចុះបញ្ចូល និងការផ្លាស់ប្រែចិត្តជឿ របស់ព្រះគម្ពីរមរមន កើតចេញមកពីការផ្ដោតសំខាន់ទាំងស្រុងទៅលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ និងភាពងាយស្រួល និងភាពច្បាស់លាស់ ដែលបំផុសគំនិតនៅក្នុងការបង្រៀនរបស់ព្រះគម្ពីរនេះ។ នីហ្វៃបានប្រកាសថា «ព្រលឹងរបស់ខ្ញុំត្រេកអរចំពោះការច្បាស់ដល់ប្រជាជនខ្ញុំ ដើម្បីឱ្យពួកគេអាចចេះដឹង» (នីហ្វៃទី 2 25:4)។ ពាក្យគន្លឹះ «ការច្បាស់» នៅក្នុងខនេះ មិនសំដៅទៅលើរឿងទាំងឡាយ ដែលសាមញ្ញ ឬធម្មតាទេ តែវាចង្អុលប្រាប់អំពីការបង្រៀនដែលច្បាស់ ហើយងាយយល់វិញ។

ព្រះគម្ពីរមរមន គឺជាគម្ពីរដ៏ត្រឹមត្រូវបំផុតជាងគម្ពីរនានាទាំងអស់ នៅលើផែនដីនេះ ដោយសារវាផ្ដោតសំខាន់ទៅលើសេចក្ដីពិត (សូមមើលយ៉ូហាន 14:6 នីហ្វៃទី 1 13:40) ជាព្រះយេស៊ូវ គ្រីស្ទ ហើយបានស្ដារឡើងវិញ នូវរឿងច្បាស់លាស់ និងដ៏មានតម្លៃ ដែលត្រូវបានដកយកចេញពីដំណឹងល្អដ៏ពិត (សូមមើល នីហ្វៃទី 1 13:26, 28—29, 32, 34—35, 40)។ ការប្រមូលផ្ដុំពិសេសនៃកត្តាទាំងពីរនេះ--- រួមមានការផ្ដោតទៅលើព្រះអង្គសង្គ្រោះ និងភាពច្បាស់លាស់នៃការបង្រៀន--- បានអញ្ជើញឱ្យមានការបញ្ជាក់ដ៏មានឥទ្ធិពល ពីសាក្សីនៃសមាជិកទីបីរបស់ក្រុមព្រះ ជាព្រះវិញ្ញាណបរិសុទ្ធ។ ដោយហេតុនេះហើយ បានជាព្រះគម្ពីរមរមន និយាយទៅកាន់វិញ្ញាណ និងដួងចិត្តរបស់អ្នកអាន ខុសពីសៀវភៅគម្ពីរផ្សេងៗទៀត។

ព្យាការីយ៉ូសែប ស្ម៊ីធ បានបង្រៀនថា ការគោរពតាមគំនិត ដែលមាននៅក្នុងព្រះគម្ពីរមរមន នឹងជួយយើង «ឱ្យខិតទៅកាន់តែជិតព្រះ» ជាងសៀវភៅណាផ្សេងទៀត (History of the Church 4:461)។ ការអាន និងការនិយាយអំពីព្រះគម្ពីរមរមនជាទៀងទាត់ អញ្ជើញអំណាច ដើម្បីតស៊ូនឹងសេចក្ដីល្បួង ហើយបង្កើតអារម្មណ៍នៃសេចក្ដីស្រឡាញ់នៅក្នុងក្រុមគ្រួសាររបស់យើង។ ហើយការពិភាក្សាអំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៅក្នុងព្រះគម្ពីរមរមន ផ្ដល់ឱកាសជាច្រើនសម្រាប់ឪពុកម្ដាយ ដើម្បីមើលថែកូនចៅ ស្ដាប់កូនចៅ រៀនមកពីកូនចៅ និងដើម្បីបង្រៀនដល់កូនចៅរបស់ពួកគេ។

យុវវ័យគ្រប់វ័យ សូម្បីតែទារក ក៏អាចឆ្លើយតបទៅនឹងវិញ្ញាណដ៏ពិសេសនៃព្រះគម្ពីរមរមនដែរ។ កុមារតូចៗ មិនអាចយល់គ្រប់ពាក្យ និងគ្រប់រឿងទេ ប៉ុន្តែពួកគេអាចទទួលអារម្មណ៍នូវ «វិញ្ញាណស្រដៀងគ្នា» ដ៏ជាក់លាក់ (អេសាយ 29:4) ដូចបានពិពណ៌នាដោយលោកអេសាយ។ ហើយសំណួរដែលកុមារតូចសួរ ការសង្កេតមើលដែលកុមារចែកចាយ និងការពិភាក្សា ដែលកើតឡើង ផ្ដល់ជាសញ្ញាព្រមានជាមុនខាងវិញ្ញាណដ៏សំខាន់។ ជាពិសេស ការសន្ទនាដូច្នេះ អាចជួយដល់ឪពុកម្ដាយ ឱ្យយល់នូវអ្វីដែលកូនចៅរបស់ពួកគេកំពុងតែរៀន គិត និងមានអារម្មណ៍អំពីសេចក្ដីពិត ដែលមាននៅក្នុងគម្ពីរពិសិដ្ឋនេះ ក៏ដូចជាការលំបាកទាំងឡាយ ដែលពួកគេអាចនឹងកំពុងប្រឈមមុខផងដែរ។

កត្តា #2៖ ការថ្លែងទីបន្ទាល់ចេញពីក្នុងចិត្តដោយឯកឯង

ទីបន្ទាល់គឺជាចំណេះដឹងផ្ទាល់ខ្លួន ផ្ដោតទៅលើសាក្សីនៃព្រះវិញ្ញាណបរិសុទ្ធថា កត្តាជាក់លាក់នៃសារៈសំខាន់ដ៏អស់កល្បជានិច្ច គឺជាការពិត។ ព្រះវិញ្ញាណបរិសុទ្ធ គឺជាអ្នកនាំសារឱ្យព្រះវរបិតា និងព្រះរាជបុត្រា ហើយជាគ្រូបង្រៀន និងដឹកនាំទៅរកសេចក្ដីពិតគ្រប់យ៉ាង (សូមមើល យ៉ូហាន 14:26; 16:13)។ ហេតុដូច្នេះ «ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ នោះអ្នករាល់គ្នាអាចស្គាល់សេចក្ដីពិតនៃគ្រប់ការណ៍ទាំងអស់» (មរ៉ូណៃ 10:5)។

ចំណេះដឹង និងការផ្លាស់ប្រែចិត្តជឿខាងវិញ្ញាណ ដែលយើងទទួលមកពីព្រះវិញ្ញាណបរិសុទ្ធ គឺជាលទ្ធផល

នៃវិវរណៈ។ ការស្វែងរក និងការទទួលបាននូវពរជ័យទាំងនេះ តំរូវឱ្យមានដួងចិត្តស្មោះស្មគ្រ័ បំណងពិត និងសេចក្តីជំនឿលើព្រះគ្រីស្ទ (សូមមើលមរ៉ូណៃ 10:4)។ ទីបន្ទាល់ផ្ទាល់ខ្លួន ក៏នាំមកនូវករណីយកិច្ច និងការទទួលខុសត្រូវផងដែរ។

ឪពុកម្តាយ គួរតែយកចិត្តទុកដាក់ដោយប្រុងប្រយ័ត្ន និង យកចិត្តទុកដាក់ខាងវិញ្ញាណ ចំពោះឱកាសដែលបានកើតឡើងដោយឯកឯង ដើម្បីថ្លែងទីបន្ទាល់ចំពោះកូនចៅរបស់ពួកគេ។ ស្ថានភាពដូច្នេះ មិនចាំបាច់ឱ្យមានជាកម្មវិធី ការដាក់កាលវិភាគ និងមានសរសេរទុកនោះទេ។ តាមពិត ការចែកចាយទីបន្ទាល់ដោយមិនចាំបាច់រៀបចំផែនការដូច្នេះ គឺកាន់តែមានឥទ្ធិពលនៃការស្អាងដ៏យូរអង្វែងយ៉ាងអស្ចារ្យ (គ. និង ស. 84:85)។

ឧទាហរណ៍ ការកើតមានការសន្ទនាជាគ្រួសារពេលបរិភោគអាហារពេលល្ងាចតាមធម្មតា អាចជាពេលដ៏ល្អបំផុតសម្រាប់ឪពុកម្តាយ ដើម្បីប្រាប់ និងថ្លែងទីបន្ទាល់អំពីពរជ័យជាក់លាក់ដែលគាត់ ឬនាងបានទទួលអំឡុងពេលសកម្មភាពតាមទម្លាប់ដែលមាន។ ហើយទីបន្ទាល់មួយ មិនចាំបាច់ចាប់ផ្តើមដោយឃ្លាថា «ខ្ញុំសូមថ្លែងទីបន្ទាល់របស់ខ្ញុំទៅកាន់អ្នក»នោះទេ។ សាក្សីរបស់យើង អាចត្រូវបានប្រកាសដោយសាមញ្ញថា៖ «ខ្ញុំដឹងថា ខ្ញុំត្រូវបានប្រទានពរដោយការបំផុសគំនិតនៅកន្លែងការងារថ្ងៃនេះ» ឬ «សេចក្តីពិតនៅក្នុងខគម្ពីរនេះ តែងតែជាប្រភពនៃការដឹកនាំខ្ញុំដ៏មានអំណាចមួយ»។ ឱកាសស្រដៀងគ្នានេះ ដើម្បីថ្លែងទីបន្ទាល់អាចកើតឡើង ពេលកំពុងធ្វើដំណើរជាមួយគ្នានៅក្នុងឡាន ឬឡានក្រុង ឬនៅស្ថានភាពដទៃទៀតជាច្រើនផងដែរ។

ប្រតិកម្មរបស់កុមារចំពោះការថ្លែងទីបន្ទាល់ដែលមិនបានត្រៀមទុក និងការចង់បាន ឬការស្ទាក់ស្ទើរក្នុងការចូលរួមរបស់ពួកគេដូច្នេះ គឺជាប្រភពដ៏រឹងមាំនៃសញ្ញាព្រមានជាមុនខាងវិញ្ញាណ។ ការបង្ហាញចំណាប់អារម្មណ៍របស់កុមារ អំពីមេរៀនដែលបានរៀន នៅក្នុងការសិក្សាព្រះគម្ពីរជាគ្រួសារ ឬសេចក្តីថ្លែងបើកបង្ហាញអំពីកង្វល់ ចំពោះគោលការណ៍ដំណឹងល្អ ឬការអនុវត្តន៍ អាចជាការបំភ្លឺ និងជំនួយដ៏សំខាន់បំផុតដល់ឪពុកម្តាយឱ្យ កាន់តែយល់អំពីសំណួរ និងសេចក្តីត្រូវការជាក់លាក់របស់កូន។ ការពិភាក្សាគ្នាដូច្នេះ---ជាពិសេស នៅពេលឪពុកម្តាយ មានចិត្តចង់ស្តាប់ដោយយកចិត្តទុកដាក់ នៅពេលពួកគេនិយាយ--- អាចជំរុញឱ្យមានបរិយាកាសគាំទ្រ និងសុវត្ថិភាពនៅក្នុងគេហដ្ឋាន និងលើកទឹកចិត្តឱ្យបន្តមានការទំនាក់ទំនងអំពីប្រធានបទពិបាកៗ។

កត្តា #3៖ការអញ្ជើញកូនៗឱ្យធ្វើសកម្មភាព

នៅក្នុងការបែងចែកដ៏ធំនៃការបង្កបង្កើតទាំងអស់របស់ព្រះ មាន «អ្វីៗដើម្បីធ្វើសកម្មភាព និងអ្វីៗដើម្បីទទួលសកម្មភាព» (នីហ្វៃទី 2 2:14)។ ក្នុងនាមជាកូនចៅរបស់ព្រះវរបិតាសួគ៌របស់យើង នោះយើង

ត្រូវបានប្រទានពរនូវអំណោយនៃសិទ្ធិជ្រើសរើសខាងសីលធម៌ ជាសមត្ថភាព និងអំណាចនៃសកម្មភាពដោយឯករាជ្យ។ ដោយបានប្រទានឱ្យជាមួយនឹងសិទ្ធិជ្រើសរើសនេះ នោះយើងគឺជាភ្នាក់ងារ ហើយសំខាន់បំផុត គឺយើងត្រូវធ្វើសកម្មភាព ហើយមិនមែនគ្រាន់តែទទួលសកម្មភាពប៉ុណ្ណោះនោះទេ--- ជាពិសេស នៅពេលយើង «...ស្វែងរកការរៀនសូត្រគឺដោយសារការសិក្សា និងដោយសារសេចក្តីជំនឿនោះ» (គ. និង ស. 88:118)។

ក្នុងនាមជាអ្នករៀនដំណឹងល្អ នោះយើងគួរតែ «ជាអ្នកប្រព្រឹត្តតាមព្រះបន្ទូល កុំឱ្យគ្រាន់តែស្តាប់ប៉ុណ្ណោះ» ឡើយ (យ៉ាកុប 1:22)។ ដួងចិត្តរបស់យើងគឺត្រូវបានបើកចំពោះព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលយើងអនុវត្តសិទ្ធិជ្រើសរើសដោយត្រឹមត្រូវ ហើយធ្វើសកម្មភាពស្របតាមគោលការណ៍ត្រឹមត្រូវ--- ហើយដោយហេតុនោះយើងអញ្ជើញអំណាចនៃការបង្រៀន និងការថ្លែងទីបន្ទាល់របស់ទ្រង់មក។ ឪពុកម្តាយមានការទទួលខុសត្រូវដ៏ពិសិដ្ឋ ដើម្បីជួយកូនចៅឱ្យធ្វើសកម្មភាព និងស្វែងរកការរៀនសូត្រដោយសេចក្តីជំនឿ។ ហើយកុមារម្នាក់ គឺមិនដែលក្មេងពេកដើម្បីមានចំណែកនៅក្នុងគំរូនៃការរៀនសូត្រនេះទេ។

ការផ្តល់ត្រីឱ្យមនុស្សម្នាក់ គឺចិញ្ចឹមគាត់នូវអាហារមួយពេល។ ការបង្រៀនឱ្យមនុស្សម្នាក់ចេះស្ទូចត្រី គឺចិញ្ចឹមគាត់ពេញមួយជីវិត។ ក្នុងនាមជាឪពុកម្តាយ និងជាអ្នកបង្រៀនដំណឹងល្អ អ្នករាល់គ្នា ហើយនឹងខ្ញុំមិនត្រូវស្ទូចត្រីឱ្យគេនោះទេ ប៉ុន្តែកិច្ចការរបស់យើង គឺដើម្បីជួយកូនចៅរបស់យើងឱ្យរៀន «ស្ទូចត្រី» ហើយមានភាពរឹងមាំខាងវិញ្ញាណ។ គោលបំណងដ៏សំខាន់នេះ នឹងត្រូវបានសម្រេចយ៉ាងល្អបំផុត នៅពេលយើងលើកទឹកចិត្តកូនចៅរបស់យើងឱ្យធ្វើសកម្មភាព ស្របទៅតាមគោលការណ៍ត្រឹមត្រូវ--- នៅពេលយើងជួយពួកគេឱ្យរៀនតាមរយៈការធ្វើសកម្មភាព (សូមមើល យ៉ូហាន 7:17)។ ការរៀនសូត្រដូច្នេះតំរូវឱ្យមានការដាស់តឿនខាងវិញ្ញាណ ខាងសតិអារម្មណ៍ និងខាងរាងកាយ ហើយមិនមែនគ្រាន់តែជាការទទួលយកដោយមិនធ្វើសកម្មភាពនោះទេ។

សូមអញ្ជើញកូនឱ្យធ្វើជាអ្នករៀនដំណឹងល្អដើម្បីធ្វើសកម្មភាព ហើយមិនមែនគ្រាន់តែទទួលសកម្មភាពទេ ដើម្បីសង់នៅលើការអាន និងការនិយាយអំពីព្រះគម្ពីរមរមន និងការថ្លែងទីបន្ទាល់ដោយមិនបាច់ត្រៀមទុកនៅក្នុងគេហដ្ឋានប៉ុណ្ណោះ។ ចូរនឹកគិតអំពីរាត្រីជួបជុំក្រុមគ្រួសារមួយ ដែលកូនៗត្រូវបានអញ្ជើញឱ្យមក ហើយរំពឹងទុកថានឹងមកដោយបានរៀបចំសំណួរដើម្បីសួរ អំពីអ្វីដែលពួកគេបានអាន និងបានរៀននៅក្នុងព្រះគម្ពីរមរមន--- ឬអំពីរឿងមួយដែលថ្មីៗនេះ ត្រូវបានគូសបញ្ជាក់នៅក្នុងការពិភាក្សាដំណឹងល្អ ឬការថ្លែងទីបន្ទាល់ដោយមិនបាច់ត្រៀមទុកនៅក្នុងគេហដ្ឋាន។ ហើយសូមនឹកស្រមៃបន្ថែមទៀត កូនៗសួរសំណួរ ដែលឪពុកម្តាយមិនបានរៀបចំខ្លួនគ្រប់គ្រាន់ដើម្បីឆ្លើយ។ ឪពុកម្តាយមួយចំនួនអាចនឹងព្រួយបារម្ភអំពីការសួរដោយសេរីនោះ នៅក្នុងរាត្រីជួបជុំក្រុមគ្រួសារ។ ប៉ុន្តែរាត្រីជួបជុំក្រុមគ្រួសារដ៏ល្អបំផុត គឺមិនចាំបាច់មានសម្ភារត្រៀមទុកជាមុន បានទិញសម្ភារ ឬដកស្រង់យកកញ្ចប់គំនូរ ឬសម្ភារជំនួយចក្ខុមកនោះទេ។ តើវាជាឱកាសដ៏រុងរឿងប៉ុណ្ណាទៅ សម្រាប់ឱ្យសមាជិកគ្រួសារ ស្រាវជ្រាវខគម្ពីរជាមួយគ្នា ស្វែងរក

ការរៀនសូត្រដោយសេចក្ដីជំនឿ ហើយត្រូវបានបង្រៀនដោយព្រះវិញ្ញាណបរិសុទ្ធនោះ។ «ត្បិតអ្នកផ្សាយសាសនាមិនប្រសើរជាងអ្នកស្ដាប់ទេ ឯគ្រូបង្រៀនក៏មិនប្រសើរជាងអ្នករៀនដែរ ...ពួកគេបានធ្វើការទាំងអស់គ្នា បុគ្គលគ្រប់រូបតាមកម្លាំងរៀងៗខ្លួន» (អាលម៉ា 1:26)។

តើអ្នករាល់គ្នា និងរូបខ្ញុំ កំពុងតែជួយដល់កូនចៅរបស់យើង ឱ្យក្លាយជាភ្នាក់ងារ ដែលធ្វើសកម្មភាព និងស្វែងរកការរៀនសូត្រដោយការសិក្សា និងសេចក្ដីជំនឿ ឬតើយើងបានបង្រៀនកូនចៅរបស់យើង ឱ្យរង់ចាំទទួលការបង្រៀន និងទទួលសកម្មភាពដែរឬទេ? តើយើងរាល់គ្នាក្នុងនាមជាឪពុកម្ដាយ ផ្ដល់ដល់កូនចៅរបស់យើង នូវគ្រឿងខាងវិញ្ញាណស្មើគ្នាដើម្បីបរិភោគជាចំបង ឬតើយើងកំពុងតែជួយពួកគេយ៉ាងខ្ជាប់ខ្ជួនដើម្បីធ្វើសកម្មភាព ដើម្បីរៀនដោយខ្លួនឯង និងដើម្បីឈរដោយខ្ជាប់ខ្ជួន និងមុតមាំដែរឬទេ? តើយើងរាល់គ្នាកំពុងតែជួយកូនចៅរបស់យើង ឱ្យមានចិត្តឧស្សាហ៍នៅក្នុងការសួរ ការស្វែងរក និងការគោះដែរឬទេ? (សូមមើល នីហ្វៃទី  3 14:7)។

ការយល់ដឹងខាងវិញ្ញាណ ដែលអ្នករាល់គ្នា ហើយនឹងរូបខ្ញុំ ត្រូវបានប្រទានឱ្យ ដើម្បីទទួល និងត្រូវបានបញ្ជាក់ជាការពិត នៅក្នុងដួងចិត្តរបស់យើង ជាធម្មតា មិនអាចត្រូវបានផ្ដល់ទៅឱ្យកូនចៅរបស់យើងទេ។ ការបង្រៀនអំពីភាពឧស្សាហ៍ និងអំពីការរៀនសូត្រដោយការសិក្សា ព្រមទាំងដោយសេចក្ដីជំនឿផងដែរនោះ ត្រូវតែមានការបង់ថ្លៃ ដើម្បីទទួលបាន និង «មាន» ចំណេះដឹងដូច្នេះផ្ទាល់ខ្លួន។ មានតែតាមវិធីនេះប៉ុណ្ណោះ ទើបអាចដឹងនៅក្នុងគំនិត ព្រមទាំងនៅក្នុងចិត្តបាន។ មានតែតាមវិធីនេះប៉ុណ្ណោះ ទើបកូនអាចផ្លាស់ចេញពីការពឹងផ្អែកលើចំណេះដឹង និងបទពិសោធន៍ខាងវិញ្ញាណ របស់ឪពុកម្ដាយ និងមនុស្សពេញវ័យ ហើយប្រកាសអំពីពរជ័យទាំងនោះ សម្រាប់ខ្លួនគាត់ ឬនាងបាន។ មានតែតាមវិធីនេះប៉ុណ្ណោះ ទើបកូនៗរបស់យើង អាចត្រូវបានរៀបចំខ្លួនខាងវិញ្ញាណ សម្រាប់ឧបសគ្គទាំងឡាយនៃជីវិតរមែងស្លាប់។

*ការសន្យា និងទីបន្ទាល់*

ខ្ញុំសូមថ្លែងជាសាក្សីថា ឪពុកម្ដាយដែលអាន និងនិយាយអំពីព្រះគម្ពីរមរមនជាមួយនឹងកូនៗរបស់ពួកគេដោយខ្ជាប់ខ្ជួន ដែលចែកចាយទីបន្ទាល់ដោយមិនបាច់ត្រៀមទុកជាមួយនឹងកូនៗរបស់ពួកគេ ហើយជាអ្នកដែលអញ្ជើញកូនៗរបស់ពួកគេ ជាអ្នកដែលជាអ្នករៀនដំណឹងល្អ ឱ្យធ្វើសកម្មភាព ហើយមិនគ្រាន់តែទទួលសកម្មភាព នឹងត្រូវបានប្រទានពរជាមួយនឹង កែវភ្នែកដែលអាចមើលឃើញបានវែងឆ្ងាយ (សូមមើលម៉ូសេ 6:27) និងត្រចៀក ដែលអាចស្ដាប់ឮសម្លេងត្រែ (សូមមើល អេសេគាល 33:2--16)។ ការដឹងខាងវិញ្ញាណ និងការបំផុសគំនិត ដែលអ្នកនឹងបានទទួលមកពីការប្រមូលផ្ដុំនូវទម្លាប់បរិសុទ្ធទាំងបីនេះជាមួយគ្នា នឹងអាចជួយដល់អ្នកឈរជាអ្នកចាំយាម នៅលើប៉ម សម្រាប់ក្រុមគ្រួសាររបស់អ្នក--- « ចាំយាមដោយនូវគ្រប់ទាំងសេចក្ដីខ្ជាប់ខ្ជួន»--- ដើម្បីពរជ័យនៃក្រុមគ្រួសារ និងកូនចៅរបស់អ្នក។ ខ្ញុំសូមសន្យាដូច្នោះ និងថ្លែងទីបន្ទាល់ នៅក្នុងព្រះនាមដ៏ពិសិដ្ឋរបស់ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ អាម៉ែន។